# មូលនិធិពុទ្ធសាសនាខ្មែរបានផ្តល់ជំនួយឥតសំណងចំនួន ១លានដុល្លារ ដើម្បីធ្វើ Digital និងប្រមូលអភិរក្សនូវសាស្ត្រាស្លឹករឹតដែលនៅសេសសល់ទាំងប៉ុន្មាន

-- ការប្រមូលឯកសារព្រះពុទ្ធសាសនាដ៏កម្រ ដែលមានអាយុកាលជាង៥០០ ឆ្នាំ ដែលនិយាយអំពីវប្បធម៌ វិទ្យាសាស្រ្ត ឱសថ ប្រវត្តិសាស្រ្ត និងសាសនា ត្រូវបានដាក់ឱ្យប្រើប្រាស់ដោយឥតគិតថ្លៃដល់សហគមន៍លើពិភពលោកតាមប្រព័ន្ធអ៊ីនធឺណិត --

San Francisco - ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ - មូលនិធិព្រះពុទ្ធសាសនាខ្មែរ ដែលមិនស្វែងរកប្រាក់កម្រៃ ៥០១(c) (៣) ដែលតែងតែអភិរក្សនូវវប្បធម៌របស់ខ្មែរ ។ យើងមានសេចក្តីសោមនស្ស ជម្រាបសាធារជនថា ក្រុមយើងបានផ្តល់ជំនួយ ១លានដុល្លារ ដល់អង្គការ **The Buddhist Digital Resource Center (BDRC)** ដែលកំពុងត្រូវការ អភិរក្ស និងស្តារឡើងវិញនូវសាស្រ្តាស្លឹករឹតចំនួន១,៥លាន ទំព័រជាឯកសារ ដែលជាការប្រមូលផ្តុំ ឯកសារទាក់ទង់នឹងព្រះពុទ្ធសាសនាខ្មែរដ៏ធំបំផុតនៅលើពិភពលោក ។

អក្សរសិល្ប៍ខ្មែរដែលមានអាយុកាលរាប់រយឆ្នាំមកនេះ គឺមាននៅក្នុងសាស្រ្តាស្លឹករឹត ។ ប្រពៃណីទំនៀមទម្លាប់អាស៊ីទក្សិណ និងអាស៊ីអាគ្នេយ៍ក្នុងរាប់សហស្សវត្សរ៍នេះ គឺគេប្រើស្លឹករឹតជាចម្អា យកស្លឹករឹតចងជាបាច់ខ្លីៗ ជារាងចតុកោណ ដែលត្រូវបានចងភ្ជាប់ជាមួយនឹងខ្សែចម្រុះពណ៌ ។ សាស្រ្តាស្លឹករឹតត្រូវបានបង្កើតឡើងដោយការសម្ងួត និងកាត់ស្លឹករឹតខ្លីៗ រួចប្រើដែកស្រួច ដើម្បីឆ្លាក់អក្សរលើផ្ទៃកទាំងពីរនៃបន្ទះនីមួយៗ របស់ស្លឹករឹត ។ តាមបែបធម្មជាតិ សាស្រ្តាស្លឹករឹតអាចងាយបំផ្លាញបាន ហើយក៏ងាយរងគ្រោះដោយសត្វល្អិត និងភ្លើង ។ ដើម្បីការពារមិនអោយបាត់បង់ឯកសារនោះ អ្នកចារនិងអ្នកចម្លងសាស្រ្តាស្លឹករឹតនោះ គឺឧស្សាហ៍ចម្លងនិងចែករំលែកចំណេះដឹង តៗពីជំនាន់មួយទៅជំនាន់មួយ  រហូតមកដល់សព្វថ្ងៃនេះ  ។ ស្លឹករឹតគឺជាប្រភពដ៏សំខាន់នៃឯកសារព្រះពុទ្ធសាសនាដែលចារិកទ្រឹស្តីរបស់ព្រះពុទ្ធនៅទីនោះ ហើយក៏មានជាវប្បធម៌ខ្មែរផងដែរ រួមទាំងប្រវត្តិសាស្រ្ត អក្សរសាស្រ្ត ហោរាសាស្រ្ត និងវេជ្ជសាស្រ្ត ជាដើម ។

គួរឱ្យសោកស្តាយ អ្នកស្រាវជ្រាវបានប៉ាន់ប្រមាណថាជាង ៩៥% នៃសាស្រ្តាស្លឹករឹតនៅកម្ពុជាបានបាត់បង់នៅចន្លោះឆ្នាំ១៩៧៥ និង ១៩៩០ ដោយសារតែការបំផ្លិច

បំផ្លាញទាំងស្រុងក្នុងរបបខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ សូម្បីតែអត្ថបទដែលនៅសេសសល់ទាំងប៉ុន្មានក៏នឹងត្រូវបាត់បង់ជាមួយនឹងពេលវេលារបស់វាដែរ ដោយសារតែខ្វះការអភិរក្ស ។

**អ្នកស្រី Lyna Lam** ជាស្ថាបនិក និងជានាយកប្រតិបត្តិនៃមូលនិធិពុទ្ធសាសនាខ្មែរ បាននិយាយថា "សាស្ត្រាស្លឹករឹតទាំងនេះមានសារៈសំខាន់សម្រាប់ការស្តារឡើងវិញនៃវប្បធម៌ខ្មែរ ដែលជាហេតុធ្វើឱ្យនាងខ្ញុំមានក្តីរំភើបយ៉ាងក្រៃលែង ពេលឃើញសាស្ត្រាស្លឹករឹតត្រូវបានស្តារឡើងវិញហើយចម្លងដាក់ក្នុងប្រព័ន្ធផ្សព្វផ្សាយ និងបានចែករំលែកជាសាធារណៈ" ។ “សាស្ត្រាស្លឹករឹតខ្លះមានអាយុកាល៥០០ ឆ្នាំ ដែលឆ្លុះបញ្ចាំងបង្ហាញអំពីវប្បធម៌ ដ៏ថ្លៃថ្នូរនៅក្នុងសង្គមខ្មែរ មុនពេលប្រទេសនេះត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម និងពិតជាមានសារៈសំខាន់ក្នុងការអប់រំមនុស្សជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រ និងវប្បធម៌ប្រពៃណីដ៏រស់រវើក ពោរពេញដោយអត្ថន័យ ” ។

លោក Jann Ronis, នាយកប្រតិបត្តិនៃ BDRC មានប្រសាសន៍ថា "ខ្ញុំសូមថ្លែងអំណរគុណចំពោះការផ្តល់ជំនួយដល់មូលនិធិនេះ ព្រោះវាអាចជួយក្រុមការងារយើងខិតខំប្រឹងប្រែងបន្តទៀតក្នុងការថែរក្សាវប្បធម៌ខ្មែរ និងចែករំលែកជាមួយសាធារណជនជាច្រើនទៀតនៅលើអ៊ីនធឺណិត" ។ “គម្រោងនេះគឺមានសារៈសំខាន់ក្នុងការរក្សានូវអក្សរសិល្ប៍មានតម្លៃ ដែលបម្រុងនឹងបាត់បង់ទៅ អោយគង់វង់យូរអង្វែង។ យើងមានមោទនភាពណាស់ចំពោះការងារដ៏អស្ចារ្យដែលធ្វើឡើងដោយក្រុមការងារក្នុងប្រទេសកម្ពុជា ដែលបានជួយយើងធ្វើការនេះដោយមិនគិតពីការនឿយហត់ នៅក្នុងតំបន់ដាច់ស្រយាលបំផុតមួយចំនួន ។ ដើម្បីស្វែងរកប្រវត្តិសាស្ត្រាស្លឹករឹត រួចប្រមូលផ្តុំ រៀបចំ និងធ្វើជាមាតិកាឡើង ដើម្បីងាយស្រួលដល់មនុស្សជំនាន់ក្រោយស្វែករកមើល ។

ការធ្វើជាឌីជីថល សាស្ត្រាស្លឹករឹតបានចាប់ផ្តើមធ្វើនៅឆ្នាំ២០១៩ ដោយការផ្តល់ជំនួយដំបូងដល់អង្គការ BDRC ពីមូលនិធិព្រះពុទ្ធសាសនាខ្មែរ ។ ត្រូវចំណាយពេលពីរឆ្នាំកន្លះ ដើម្បីកំណត់ទីតាំង និងសម្អាត រៀបចំ និងស្កេនអត្ថបទ ។ សរុបមកស្លឹករឹតចំនួន ១១,០០០ សន្លឹកត្រូវបានបំប្លែងជាឌីជីថល ហើយបច្ចុប្បន្នភាពជាង ៨,៦០០ សន្លឹកដែលមាននៅលើអ៊ីនធឺណិតសម្រាប់មើល និងអាចទាញយកដោយឥតគិតថ្លៃ ។ នៅសល់ ២,៥០០ នឹងត្រូវបានដំណើរការ និងចេញផ្សាយតាមអ៊ីនធឺណិតនៅប៉ុន្មានខែខាងមុខនេះ។ ដើម្បីងាយស្រួលក្នុងការចូលប្រើប្រាស់ BDRC កំពុងតែជួយធ្វើឱ្យសាស្ត្រាស្លឹករឹតខ្មែរ អាចអានតាមរយៈគេហទំព័រដើមនេះ និង

យកទៅផ្សាយបន្តដោយខ្លួនឯងសម្រាប់សហគមន៍ខ្មែរ ទូទាំងពិភពលោកបាន
http://khmer-manuscripts.bdrc.io
(កំពុងដំណើរការ)

**Lyna** និយាយថា "វាជាកិច្ចការដ៏ធំធេងណាស់" ។ “BDRC បានឆ្លងកាត់ និងធ្វើលើសពីនេះទៀត ដើម្បីកំណត់ទីតាំងវត្ថុបុរាណសំខាន់ៗទាំងនោះ បន្ទាប់មក ថតរូប រក្សាទុក និងបង្កើតមាតិកា ដើម្បីងាយចែករំលែកជាមួយអ្នកដទៃ ។ យើងសូមកោតសរសើរ និងថ្លែងអំណរគុណចំពោះការខិតខំឧស្សាហ៍ព្យាយាម និងការយកចិត្តទុកដាក់របស់ពួកគេ»។

គម្រោងអភិរក្សមានច្រើនជាងគេគឺការថតរូបភាពសាស្ត្រាស្លឹករឹត ខណៈពេលដែលទម្រង់នោះមាន ៧០%នៃសាស្ត្រាស្លឹករឹតត្រូវបានធ្វើជា Digital នៅសេសសល់រួមមានខ្សែភាពយន្តរាប់រយខ្សែដែលផលិតដោយ École française d'Extrême-Orient ចន្លោះឆ្នាំ ១៩៩០ និង ២០១២ ។ អត្ថបទស្លឹករឹតជាច្រើនដែលចងក្រងជាឯកសារនៅក្នុងខ្សែភាពយន្តទាំងនេះបានបាត់បង់និងរាត់រាយតាំងពីពេលនោះមក ។ ហើយដោយសារតែឯកសារទាំងនេះត្រូវបានរក្សាទុកនៅក្នុងប្រអប់នៅក្នុងការិយាល័យដែលមិនមានការមើលថែត្រឹមត្រូវបូកផ្សំនឹងអាកាសធាតុនៅក្នុងប្រទេសកម្ពុជាទៀត, ខ្សែអាត់ - ច្បាប់ចម្លងតែមួយគត់ដែលនៅសល់ - ខូចគុណភាព និងប្រឈមនឹងហានិភ័យនៃការបាត់បង់ផងដែរ ដោយគ្មានការអភិរក្សត្រឹមត្រូវ ។

ប្រភពឯកសារ Digital ថ្មីនេះ មិនត្រឹមតែជួយរក្សាទុកឯកសារដែលមិនអាចកាត់ថ្លៃបានរបស់សង្គមកម្ពុជាប៉ុណ្ណោះទេ លើសពីនោះទៀត វាជួយឱ្យអ្នកអានសម័យទំនើបនេះ នៅមានភាពងាយស្រួលដើម្បីចូលរកឯកសារព្រះពុទ្ធសាសនាខ្មែរផងដែរ ។ គេហទំព័រនេះក៏មានតម្លៃសម្រាប់អ្នកប្រាជ្ញ និងព្រះសង្ឃ បន្តស្រាវជ្រាវអំពីប្រពៃណីវប្បធម៌ក្នុងការសិក្សាស្វែងរកនូវអត្ថបទចាស់ៗ ទាំងនេះផងដែរ ។ ជំហានបន្ទាប់របស់គម្រោងនេះគឺបង្កើតខ្លឹមសារបន្ថែម និងវីដេអូ /ភាពយន្តឯកសារខ្លីៗ ដែលពិពណ៌នា និងពន្យល់អំពីរបៀបធ្វើសាស្ត្រាស្លឹករឹត រួមទាំងសិល្ប: ហត្ថកម្ម និងប្រពៃណីរបស់ប្រជាជនខ្មែរ ។

អំពី មូលនិធិព្រះពុទ្ធសាសនាខ្មែរ
មូលនិធិពុទ្ធសាសនិកជនខ្មែរ គឺជាអង្គការមិនរកប្រាក់កម្រៃមួយ គឺផ្តោតទៅលើការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ និងថែរក្សាប្រពៃណី និងវប្បធម៌ដ៏សម្បូរបែបរបស់ខ្មែរប៉ុណ្ណោះ ។ យើងបានផ្តល់ជំនួយជារៀងរាល់ឆ្នាំ ដើម្បីពង្រឹង

និងពង្រីកជីវភាពរស់នៅរបស់ប្រជាជនខ្មែរ លើវិស័យនានាដែលរួមមានសិល្បៈ វប្បធម៌ និងសេដ្ឋកិច្ច ។ ស្វែងយល់បន្ថែម៖ www.akhmerbuddhistfoundation.org

អំពីអង្គការ **Buddhist Digital Resource Center**

មជ្ឈមណ្ឌលពិភពឌីជីថលព្រះពុទ្ធសាសនា **(BDRC)** គឺជាអង្គការមិនរកប្រាក់កម្រៃ ដែលជំនាញខាងស្រាវជ្រាវស្វែងរក ថែរក្សា ចងក្រងឯកសារ និងផ្សព្វផ្សាយអក្សរសាស្ត្រព្រះពុទ្ធសាសនា ។ អង្គការជួយផ្តល់ឱ្យអ្នកប្រាជ្ញ អ្នកបកប្រែ ពុទ្ធសាសនិកជន និងសាធារណជនទូទៅមានភាពងាយស្រួលក្នុងការស្វែងរកបណ្តុំនៃអត្ថបទឯកសារព្រះពុទ្ធសាសនាដ៏មានតម្លៃ ។ ចូលរួមជាមួយបច្ចេកវិទ្យាឌីជីថលជាមួយនឹងអាហារូបករណ៍ **BDRC** ធានាថាសម្បត្តិវប្បធម៌នៃប្រពៃណីអក្សរសាស្ត្រព្រះពុទ្ធសាសនាបានគង់វង់ និងអាចបន្តចែកចាយដល់មនុស្សជំនាន់ក្រោយ ។
ស្វែងយល់បន្ថែម៖ www.bdrc.io

**ទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយ៖**

**Birgit Johnston** សម្រាប់មូលនិធិព្រះពុទ្ធសាសនាខ្មែរ
**birgitjohnston@me.com, (408) 656 8025**